# គោលការណ៍ណែនាំអំពីជំនួយជាប្រាក់ – សេចក្តីសង្ខេបជាភាសាសាមញ្ញ

**Mayo Clinic និងមន្ទីរពេទ្យ និងគ្លីនិកដែលជាប់ពាក់ព័ន្ធនានា**

Financial Assistance Policy – Plain Language Summary (Khmer)
Mayo Clinic and Affiliated Hospitals and Clinics

## ជំនួយជាប្រាក់ដែលបានផ្តល់ជូន

Mayo Clinic ផ្តល់ជូនការថែទាំដ៏ល្អឥតខ្ចោះសម្រាប់អ្នកជំងឺគ្រប់រូប ហើយផ្តល់ជូនជំនួយជាប្រាក់ដល់អ្នកជំងឺ ដែលមិនអាចបង់ប្រាក់សម្រាប់ការសង្គ្រោះបន្ទាន់ ឬការថែទាំសុខភាពចាំបាច់បាន។

## លក្ខខណ្ឌតម្រូវចំពោះសិទ្ធិទទួលបាន និងជំនួយដែលផ្តល់ជូន

Mayo Clinic ពិនិត្យមើលកត្តាជាច្រើន ដើម្បីសម្រេចថាតើអ្នកមានលក្ខណៈគ្រប់គ្រាន់សម្រាប់ជំនួយជាប្រាក់នេះដែរឬទេ។ ទាំងនេះរួមមានទាំងស្ថានភាពសុខភាព ប្រភេទនៃការថែទាំសុខភាពចាំបាច់ ក្រុម ហ៊ុន ធានារ៉ាប់រងរបស់អ្នក និងប្រភពនៃការបង់ប្រាក់ផ្សេងៗដូចជាសំណងពីការរងរបួសបុគ្គល ប្រភេទទាំងអស់នៃប្រាក់ចំណូលក្នុងផ្ទះរបស់អ្នក ទំហំគ្រួសារ ទ្រព្យសម្បត្តិគ្រួសារ និងបញ្ហាពិសេសនានាណាមួយដែលអ្នកចង់ឱ្យមានការពិចារណា។

ជំនួយជាប្រាក់អាចរកបានដោយមិនគិតពីក្រុមហ៊ុនធានារ៉ាប់រងនោះទេ។ កម្រិតនៃជំនួយជាប្រាក់អាស្រ័យលើលទ្ធភាពរបស់អ្នកក្នុងការបង់ប្រាក់ដែលគិតមកលើអ្នក។ ទោះជាយ៉ាងណា ជំនួយជាប្រាក់មិនអាចរកបានសម្រាប់គ្រប់ការថែទាំសុខភាព ដូចជាការវះកាត់កែសម្ផស្ស ការព្យាបាលយកកូន ការវះកាត់សម្រកទម្ងន់ និងទំនិញដើម្បីភាពងាយស្រួលដល់អ្នកជំងឺនោះទេ។ អ្នកមិនអាចទទួលបានជំនួយជាប្រាក់សម្រាប់ការថែទាំដែលមិនមែនជាករណីអាសន្ននោះទេ ប្រសិនបើ Mayo Clinic ស្ថិតនៅក្រៅបណ្តាញនៃក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក។ ភាពជាពលរដ្ឋ លំនៅឋាន និងស្ថានភាពទិដ្ឋាការក៏អាចនឹងជះឥទ្ធិពលលើសិទ្ធិទទួលបានរបស់អ្នកផងដែរ។

បច្ចុប្បន្ន ប្រសិនបើអ្នកបានចុះឈ្មោះនៅក្នុងជំនួយរបស់ Medicaid ឬ Medical គេអាចនឹងសន្មតជាមុនថា អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ជំនួយជាប្រាក់។ គេក៏អាចសន្មតជាមុនថា អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយផ្អែកលើព័ត៌មានផ្សេងៗដែល Mayo Clinic បានដឹង។ Mayo Clinic នឹងជូនដំណឹងដល់អ្នក ប្រសិនបើមានការកំណត់សិទ្ធិដោយការសន្មតជាមុននោះ។

ប្រសិនបើគេមិនសន្មតជាមុនថាអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះ អ្នកត្រូវតែចូលរួមជាមួយដំណើរការដាក់ពាក្យស្នើសុំទាំងស្រុងរួមបញ្ចូលទាំងការបញ្ជូនឯកសារប្រកាសពន្ធ របាយការណ៍ធនាគារ និងវិក្កយបត្រទទួលប្រាក់ឈ្នួល។ អ្នកត្រូវតែបំពេញពាក្យស្នើសុំសម្រាប់ជំនួយ Medicaid ឬ Medical ឬប្រភេទការធានារ៉ាប់រងផ្សេងៗតាមរយៈទីផ្សារនៃការធានារ៉ាប់រងសុខភាពរបស់រដ្ឋ។ សូមមើលគោលការណ៍ជំនួយជាប្រាក់ទាំងស្រុងសម្រាប់ព័ត៌មានលម្អិត។

## របៀបស្នើសុំជំនួយជាប្រាក់

អ្នក ឬបុគ្គលណាម្នាក់ដែលជាប់ពាក់ព័ន្ធនឹងការថែទាំរបស់អ្នក ដូចជាសមាជិកគ្រួសារ ឬអ្នកផ្តល់សេវាអាចលើកយកកង្វល់អំពីប្រាក់កាសនានាបានគ្រប់ពេលក្នុងអំឡុងពេលថែទាំសុខភាពរបស់អ្នក។ បន្ទាប់មក យើងលើកទឹកចិត្តឱ្យអ្នកបំពេញពាក្យស្នើសុំជំនួយជាប្រាក់ប្រសិនបើចាំបាច់។

ជំនួយជាប្រាក់ប្រើបានចំពោះតែការថែទាំសុខភាពដែលអ្នកទទួលបាននៅទីតាំងមន្ទីរពេទ្យ Mayo Clinic ពីបុគ្គលិក Mayo Clinic ប៉ុណ្ណោះ។ ថ្លៃចំណាយដូចជា ការធ្វើដំណើរ អាហារ កន្លែងស្នាក់នៅ ឧបករណ៍ពេទ្យ និងវេជ្ជបញ្ជាមិនត្រូវបានរ៉ាប់រងនៅក្រោមគោលការណ៍ជំនួយជាប្រាក់នេះទេ។ Mayo Clinic ការពារការសម្ងាត់ និងភាពថ្លៃថ្នូររបស់អ្នកក្នុងដំណើរការនេះ។ ព័ត៌មានណាមួយដែលបានផ្តល់ជូនដោយអ្នកនឹងត្រូវចាត់ទុកជាព័ត៌មានសុខភាពដែលត្រូវបានការពារក្រោមច្បាប់ស្តីពីទំនួលខុសត្រូវនិងការធានារ៉ាប់រងសុខភាពដែលអាចផ្ទេរបាន (HIPAA)។

## កន្លែងទទួលបានច្បាប់ចម្លង

អ្នកអាចទទួលបានគោលការណ៍ជំនួយជាប្រាក់ និងពាក្យស្នើសុំរបស់ Mayo Clinic ដោយឥតគិតថ្លៃ ដោយទូរសព្ទទៅសេវាបម្រើអ្នកជំងឺតាមរយៈលេខ 1-844-217-9591 ហើយស្នើសុំច្បាប់សម្លងតាមប្រៃសណីយ៍ ឬតាមអ៊ីមែល។ គោលការណ៍ និងពាក្យស្នើសុំក៏អាចរកបានតាមអនឡាញសម្រាប់ទាញយក និងព្រីនចេញ។ សម្រាប់ទីក្រុង Arizona, Florida និង Rochester សូមចូលមើលគេហទំព័រ mayoclinic.org/financialassistance ហើយសម្រាប់ទីតាំងប្រព័ន្ធសុខាភិបាលរបស់ Mayo Clinic សូមចូលមើលគេហទំព័រ mayoclinichealthsystem.org/financial-assistance។ ច្បាប់ចម្លងនៃគោលការណ៍ និងពាក្យស្នើសុំក៏អាចរកបាននៅតំបន់សេវាកម្មពាណិជ្ជកម្ម និងផ្នែកចូលសម្រាកមន្ទីរពេទ្យសម្រាប់គ្លីនិក និងមន្ទីរពេទ្យ Mayo Clinic និងទីតាំងផ្នែកសង្គ្រោះបន្ទាន់ទាំងអស់។

## សូមទាក់ទងដើម្បីទទួលបានព័ត៌មាន និងជំនួយ

អ្នកអាចទទួលបានព័ត៌មានបន្ថែមអំពីគោលការណ៍ជំនួយជាប្រាក់ និងជំនួយសម្រាប់ដំណើរការដាក់ពាក្យស្នើសុំពីសេវាបម្រើអ្នកជំងឺៈ

- តាមអនឡាញសម្រាប់ទីក្រុង Arizona, Florida និង Rochester តាមរយៈគេហទំព័រ mayoclinic.org/financialassistance ហើយសម្រាប់ទីតាំងប្រព័ន្ធសុខាភិបាលរបស់ Mayo Clinic តាមរយៈគេហទំព័រ mayoclinichealthsystem.org/financial-assistance។
- អ្នកក៏អាចទូរសព្ទទៅលេខ 1-844-217-9591 ឬទៅកាន់ទីតាំងចុះឈ្មោះ និងសេវាកម្មពាណិជ្ជកម្មក្នុងតំបន់។

©2024 Mayo Foundation for Medical Education and Research

## សម្រាប់អ្នកដែលមិននិយាយភាសាអង់គ្លេស

ការបកប្រែអំពីគោលការណ៍ជំនួយជាប្រាក់ ពាក្យស្នើសុំគោលការណ៍ជំនួយជាប្រាក់ និងសេចក្តីសង្ខេបជាភាសាសាមញ្ញនេះ អាចរកបានសម្រាប់ទីក្រុង Arizona, Florida និង Rochester តាមរយៈគេហទំព័រ mayoclinic.org/financialassistance ហើយសម្រាប់ទីតាំងប្រព័ន្ធសុខាភិបាលរបស់ Mayo Clinic តាមរយៈគេហទំព័រ mayoclinichealthsystem.org/financial-assistance។

## មិនលើសពីចំនួនដែលគិតថ្លៃជាទូទៅ (AGB)

ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ជំនួយជាប្រាក់ គេមិនអាចគិតប្រាក់ពីអ្នកច្រើនជាងចំនួនទឹកប្រាក់ដែលចេញក្នុងវិក្កយបត្រជាទូទៅសម្រាប់ករណីសង្គ្រោះបន្ទាន់ ឬការថែទាំចាំបាច់ផ្នែកសុខភាពផ្សេងទៀតដល់អ្នកជំងឺដែលមានការធានារ៉ាប់រងនោះទេ។



MC5815-26KMrev0524